ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | | |
|---|---|---|---|---|
| ៣ | លោកឧត្តមសេនីយ៍ទោ | តុល | គឹមលី | អត្តលេខ ០៣៦១ |
| ៤ | លោកឧត្តមសេនីយ៍ទោ | បូរីសាន | ដីឡូប៉េស | អត្តលេខ ០២៧៧ |
| ៥ | លោកឧត្តមសេនីយ៍ត្រី | លឹម | នឿន | អត្តលេខ ០៧១៦ |
| ៦ | លោកឧត្តមសេនីយ៍ត្រី | ប្រុក | ម៉ៃឧត្តម | អត្តលេខ ១២១៣៨ |
| ៧ | លោកឧត្តមសេនីយ៍ត្រី | កែវ | ភារាពង្ស | អត្តលេខ ០១៤៥៧ |
| ៨ | លោកឧត្តមសេនីយ៍ត្រី | ហ៊ីង | ច័ន្ទតារា | អត្តលេខ ០២៨២ |
| ៩ | លោកឧត្តមសេនីយ៍ត្រី | មួង | សុជា | អត្តលេខ ០៦៧៨ |
| ១០ | លោកវរសេនីយ៍ឯក | ទិត្យ | ប៊ុនណា | អត្តលេខ ០៦៩៦ |
| ១១ | លោកវរសេនីយ៍ឯក | ហង្ស | សុផាណារ៉ា | អត្តលេខ ០៦៩៤ |
| ១២ | លោកវរសេនីយ៍ឯក | សរ | វ៉ាន់ថុន | អត្តលេខ ០២៩៥៩ |
| ១៣ | លោកវរសេនីយ៍ឯក | ឈុន | ចាន់សុខា | អត្តលេខ ០៦៩៨ |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

*ពរល. ១០១២. ៩៣២*

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០*

លេខៈ ៨១៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ចិនតេន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពី
## ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# សម្រេច

**មាត្រាមួយ.-**

មាត្រា១២ នៃអនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា ១២ថ្មី.-**

ក្នុងអាណត្តិ នៃក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាត្រូវកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឱ្យបានយ៉ាងយូរបំផុតក្នុងឆ្នាំទី២សម្រាប់រដ្ឋបាលរបស់ខ្លួន។ កម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល :__

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រាបី*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១៨៣. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃ ស្នួល ស្ថិតក្នុងភូមិសាស្ត្រឃុំ ពីរធ្នូ ស្រុក ស្នួល ខេត្ត ក្រចេះ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

មាត្រា១:

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃ ស្នួល លើផ្ទៃដីទំហំ ២.២៥១ (ពីរពាន់ពីររយហាសិប)ហិកតា ទៅជាតំបន់សហគមន៍ ស្ថិតនៅក្នុងឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ ។

មាត្រា២:

តំបន់សហគមន៍ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោម:

| Nº | X | Y | Nº | X | Y |
|---|---|---|---|---|---|
| A | ៦៨៨៨១៧ | ១៣៤២៨៨៥ | F | ៦៩៤១០៣ | ១៣៤០១០៨ |
| B | ៦៩០០០០ | ១៣៤២៤២៧ | G | ៦៩២៩៨៥ | ១៣៣៨៧៣១ |
| C | ៦៩៤០០០ | ១៣៤២៦៥៦ | H | ៦៨៩៩៧៩ | ១៣៣៨៧២៤ |
| D | ៦៩៦០០៥ | ១៣៤១៣៩៣ | I | ៦៨៨៨០៩ | ១៣៣៩៤៧១ |
| E | ៦៩៥៣២៩ | ១៣៣៩៧៣៣ | | | |

មាត្រា៣:

ការកំណត់តំបន់សហគមន៍ស្ថិតក្នុងភូមិសាស្រ្តឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ ជាតំបន់គ្រប់គ្រងបម្រើឲ្យការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋានដែលកំពុងមានសកម្មភាពស្រាប់ រួមមានៈ លំនៅឋាន ស្រែចម្ការ។ រាល់ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឲ្យប្រើប្រាស់ដីធ្លី នៅក្នុងតំបន់សហគមន៍នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល ។

មាត្រា៤:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៥:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ...០៦... ខែ ...ធ្នូ...... ឆ្នាំ ២០១០.

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមានគ្រា ៥
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ




| ID | N | X | Y |
|---|---|---|---|
| 1 | A | 688817 | 1342885 |
| 2 | B | 690000 | 1342427 |
| 3 | C | 694000 | 1342656 |
| 4 | D | 696005 | 1341393 |
| 5 | E | 695329 | 1339733 |
| 6 | F | 694103 | 1340108 |
| 7 | G | 692985 | 1338731 |
| 8 | H | 689979 | 1338724 |
| 9 | I | 688809 | 1339471 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## <u>សម្រេច</u>

### មាត្រា១._

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ ៥.០០០ហិកតា (ប្រាំពាន់ហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅក្នុងឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន សុវណ្ណ វុទ្ធី (Sovann Vuthy Co., Ltd.) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ។

### មាត្រា២._

តំបន់ប្រើប្រាស់ដោយចីរភាពក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ក្នុងឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោមៈ

| No. | X | Y | No. | X | Y |
|---|---|---|---|---|---|
| A | 678 599 | 134 0296 | G | 683 213 | 134 3124 |
| B | 678 980 | 133 8745 | H | 680 470 | 134 2564 |
| C | 684 009 | 134 0002 | I | 678 389 | 134 2860 |
| D | 687 973 | 133 9997 | J | 678 004 | 134 2134 |
| E | 688 809 | 133 9471 | K | 671 000 | 134 2136 |
| F | 688 817 | 134 2885 | L | 671 001 | 134 0683 |

**មាត្រា៣.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ផែនទីកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់ផ្តល់ជូនក្រុមហ៊ុន សុវណ្ណ វុទ្ធី ( Sovann Vuthy Co., Ltd ) ស្ថិតក្នុងភូមិសាស្ត្រឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ លើផ្ទៃដី ៥០០០ ហ.ត




អនុក្រឹត្យ លេខ ១៥៤ អនក្រ.បក
ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០

សញ្ញាសំគាល់

- ចំណុចនិយាមកា
- ទីតាំងដីវិនិយោគ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង, អូរ
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

| ID | N | X | Y |
|---|---|---|---|
| 1 | A | 678599 | 1340296 |
| 2 | B | 678980 | 1338745 |
| 3 | C | 684009 | 1340002 |
| 4 | D | 687973 | 1339997 |
| 5 | E | 688809 | 1339471 |
| 6 | F | 688817 | 1342885 |
| 7 | G | 683213 | 1343124 |
| 8 | H | 680470 | 1342564 |
| 9 | I | 678389 | 1342860 |
| 10 | J | 678004 | 1342134 |
| 11 | K | 671000 | 1342136 |
| 12 | L | 671001 | 1340683 |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៥៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ម៉ាក ថូម៉ាស ចេនី** (Mr.Mc.Thomas Jenni) តំណាងម្ចាស់ជំនួយស្វីស សមាគមសំរេចសុបិន្តកុមារ (Child`s Dream Foundation) ដែលបានផ្តល់ថវិកាជួយកសាងអគារសិក្សា នៅសាលាបឋមសិក្សាប្រាសាទបី ឃុំបេង ចំនួន០១ខ្នងមាន០៦បន្ទប់ សាលាបឋមសិក្សាសឹង្ហឃុំគោកមនចំនួន០១ខ្នងមាន០៥បន្ទប់ និងនៅសាលាបឋមសិក្សាក្តុលឃុំអំពិលចំនួន០១ខ្នងមាន០៥បន្ទប់ ដោយមានបំពាក់សម្ភារៈសិក្សាគ្រប់ចំនួននិងសមិទ្ធផលផ្សេងៗមួយចំនួនទៀត នៅក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ចំណាយអស់ទឹកប្រាក់សរុបចំនួន ១២៤.២៧២ ដុល្លារ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមាន-ជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ... ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនលោក គីម យ៉ុងហូ (Mr. KIM YONGHO) ប្រធានសមាគមសប្បុរសជនកូរ៉េ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា០១ខ្នង មាន០៥បន្ទប់ ធ្វើខ្លោងទ្វារ ដងទង់ជាតិ បង្គន់អនាម័យ ព្រមទាំងបំពាក់សម្ភារៈគ្រូ និងសិស្ស នៅអនុវិទ្យាល័យបាសាក់ ឃុំព្រែកជីក ស្រុករុក្ខគីរី ខេត្តបាត់ដំបង ចំណាយអស់ថវិកា សរុបចំនួន ៥០.០០០ ដុល្លារអាមេរិក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៥៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ជូនលោកបណ្ឌិត Andreas Reinecke ដែលបានផ្តល់វិភាគទានជាថវិកា ជួយជួសជុលនិងសិក្សាស្រាវជ្រាវស្ថានីយ៍បុរាណព្រហារ នៅក្នុងខេត្តព្រៃវែង ចំណាយអស់ទឹកប្រាក់សរុប ចំនួន ៧៩.៨៤៦ ដុល្លារអាមេរិក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៥៧.១១ អនក្រ.ពស

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនតំណាងអង្គការ KAKO និងសមាគមសំរេចសុបិន្តកុមារ ចំនួន០៤រូប ដែលផ្តល់ថវិកាជួយកសាងអគារសិក្សា នៅសាលាបឋមសិក្សាប្រាសាទបី ឃុំបេង ចំនួន០១ខ្នង មាន០៦បន្ទប់ សាលាបឋមសិក្សាសីង្ហ ឃុំគោកមន ចំនួន០១ខ្នង មាន០៥បន្ទប់ និងនៅសាលាបឋមសិក្សាក្តុល ឃុំអំពិល ចំនួន០១ខ្នង មាន០៥បន្ទប់ ដោយមានបំពាក់សម្ភារៈសិក្សាគ្រប់ចំនួន និងសមិទ្ធផលផ្សេងៗមួយចំនួនទៀត នៅក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

-អ្នកស្រី ហែ សុវណ្ណ នាយិកាអង្គការ KAKO ខ្មែរអរតិវឌ្ឍន៍ខ្មែរ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

១-លោក ចំពេញ ស្វែងឌី ប្រធានសំរបសំរួល អង្គការ KAKO
២-លោក ស៊ាង សុខុម ប្រធានគ្រប់គ្រងគំរោង អង្គការ KAKO
៣-លោក ឃ្លោក យ៉េម ប្រធានសំរបសំរួល សមាគមសំរេចសុបិន្តកុមារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ប្រគេននិងជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ កុដិថ្មី សាលាឆាន់ របងវត្ត និង សមិទ្ធផលផ្សេងៗជាច្រើនទៀត ព្រមទាំងជួយដោះស្រាយលំនៅដ្ឋានប្រជាពលរដ្ឋ ចំនួន៧០ខ្នង ពីដីបរិវេណវត្ត នៅវត្តឥន្ទ្រាធិបតីធារាម ( ហៅវត្តសង្កែ ) សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

១-ព្រះតេជគុណ ផាត់ សារ៉ាយ ទីប្រឹក្សាព្រះចៅអធិការវត្តឥន្ទ្រាធិបតីធារាម និងជាតំណាងអោយសប្បុរសជននៅក្រៅប្រទេស បច្ច័យចំនួន ១០០.៤៥០ ដុល្លារ

២-ព្រះតេជគុណ យ៉ាន់ ម៉ូរ៉ា ព្រះចៅអធិការវត្តឥន្ទ្រាធិបតីធារាម និងជាតំណាងអោយសប្បុរសជននៅក្រៅប្រទេស បច្ច័យចំនួន ៩៥.០០០ ដុល្លារ

៣-ឧបាសិកា គង់ ខិនហោ សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ៨២.៧២៦ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១០

[illegible] នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៥៩ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ កុដិថ្មី សាលាឆាន់ របងវត្ត និង សមិទ្ធផលផ្សេងៗជាច្រើនទៀត ព្រមទាំងជួយដោះស្រាយលំនៅដ្ឋានប្រជាពលរដ្ឋ ចំនួន៧០ខ្នង ពីដីបរិវេណវត្ត នៅវត្តឥន្ទ្រាធិបតីធារាម ( ហៅវត្តសង្កែ ) សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិៈ**

១-ឧបាសក លន់ ស្រ៊ាន សប្បុរសជននៅខេត្តបាត់ដំបង ថវិកាចំនួន ៤៨.៥០០ ដុល្លារ
២-ឧបាសក ហុក ឈៀប ប្រធានគណៈកម្មការវត្តឥន្ទ្រាធិបតីធារាម ថវិកាចំនួន៤៧.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិៈ**

១-ឧបាសក អ៊ុក មិត្ត អនុប្រធានគណៈកម្មការវត្តឥន្ទ្រាធិបតីធារាម និងជាតំណាងអោយសប្បុរសជននៅក្រៅប្រទេស ថវិកា ចំនួន ៩.០០០ ដុល្លារ
២-ឧបាសក វាន វ៉ាន សមាជិកគណៈកម្មការវត្តឥន្ទ្រាធិបតីធារាម និងជាតំណាងអោយសប្បុរសជននៅក្រៅប្រទេស ថវិកា ចំនួន ៨.០០០ ដុល្លារ
៣-ឧបាសក អ៊ួន បូរ៉ាដា សមាជិកគណៈកម្មការវត្តឥន្ទ្រាធិបតីធារាម និងជាតំណាងអោយ សប្បុរសជននៅក្រៅប្រទេស ថវិកា ចំនួន ៧.០០០ ដុល្លារ

៤-ឧបាសក ស៊ាន យ៉ុង សមាជិកគណៈកម្មការវត្តឥន្ទ្រាធិបតីធារាម និង ជាតំណាងអោយសប្បុរសជន នៅក្រៅប្រទេស ថវិកា ចំនួន ៦.៥០០ ដុល្លារ

៥-ឧបាសក ម៉ែន សុខុម ប្រធានអាចារ្យវត្តឥន្ទ្រាធិបតីធារាម និងជាតំណាងអោយសប្បុរសជន នៅក្រៅប្រទេស ថវិកា ចំនួន ៦.០០០ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិៈ

១-ឧបាសក ទុំ ឃឿន អតីតអាចារ្យវត្តឥន្ទ្រាធិបតីធារាម និង ជាតំណាងអោយសប្បុរសជន នៅក្រៅប្រទេស ថវិកា ចំនួន ៤.៥០០ ដុល្លារ

២-ឧបាសក សួស គួយ អតីតសមាជិកគណៈកម្មការវត្តឥន្ទ្រាធិបតីធារាម និងជាតំណាងអោយ សប្បុរសជននៅក្រៅប្រទេស ថវិកា ចំនួន ៤.០០០ ដុល្លារ

៣-ឧបាសក ឌុក ម៉ុនឈឿន អតីតគណៈកម្មការអាចារ្យវត្តឥន្ទ្រាធិបតីធារាម និងជាតំណាងអោយ សប្បុរសជន នៅក្រៅប្រទេស ថវិកា ចំនួន ៣.៥០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៧០ . អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ហាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ហាបនាជាតិ** ជូនលោក Moriai Sachiko ដែលបានផ្តល់ថវិកា ចំនួន ៦០.៦០០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារបណ្ណាល័យ ០១ខ្នង មាន០១បន្ទប់ ព្រមទាំងបំពាក់បរិក្ខារគ្រប់គ្រាន់ ជូនដល់សាលាបឋមសិក្សា ហ៊ុន សែន គំរូ ស្ថិតនៅឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១១៦១.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក Sala Enrico ប្រធានគម្រោង Sala Enrico Et Copains Suisses ដែលបានផ្តល់ថវិកា ចំនួន ៣៣.៧៥០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន ០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់វិទ្យាល័យពួក ស្ថិតនៅឃុំពួក ស្រុកពួក ខេត្តសៀមរាប ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦៦២ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ JHP ដែលបានផ្តល់ថវិកា ចំនួន ៥៧.៤៣៣ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០៤បន្ទប់ ព្រមទាំងបំពាក់បរិក្ខារគ្រប់គ្រាន់ ជូនដល់សាលាបឋមសិក្សាស្រះជីនាង ស្ថិតនៅឃុំឫស្សីក្រាំង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៦៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណ:រដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនកញ្ញា **ជៀក ដាវណ្ណា** ដែលបានផ្តល់ថវិកាចំនួន ៣០.៤៩៦ ដុល្លារអាមេរិក ក្នុងការជួយកសាងទីចាត់ការ ចំនួន០១ខ្នង ធ្វើពីថ្ម ប្រក់ក្បឿង មានទំហំ ១៨ម x ១៦ម ជូនដល់អនុវិទ្យាល័យទីរួមខេត្ត ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណ:រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណ:អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៦៤ .អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានផ្តល់ថវិកាសរុបចំនួន ៣២.០០០ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ចំនួន០២ខ្នង មាន០៦បន្ទប់ ធ្វើពីថ្មប្រក់ក្បឿង ជូនដល់សាលាបឋមសិក្សាវត្តល្វង ស្ថិតក្នុងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិៈ

១-លោកយាយ មាស សៅយុត សប្បុរសជនខ្មែររស់នៅប្រទេសបារាំង

២-លោក នេត ចំរើន សប្បុរសជនខ្មែររស់នៅប្រទេសបារាំង

ខ-មេដាយប្រាក់ស្ថាបនាជាតិៈ

-លោក សេង ឡឿម សប្បុរសជនខ្មែររស់នៅប្រទេសបារាំង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៦៥.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនលោក ស៊ឹម ទាចា ដែលបានផ្តល់ថវិកាចំនួន ២០.០០០ ដុល្លារ ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ និងធ្វើខ្លោងទ្វារ ០១ ជូនដល់សាលាបឋមសិក្សាពពក ស្ថិតនៅឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៦៦ . អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

មាត្រា ១._

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប នៃអង្គការ អផ្ទហ្វាន់ ដែលបានចូលរួមជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ បង្គន់អនាម័យ ០២បន្ទប់ និងអណ្តូងទឹក០១ ព្រមទាំងផ្តល់សម្ភារៈសិក្សាមួយចំនួន និងសំលៀកបំពាក់ សម្រាប់សិស្សានុសិស្ស ចំនួន១៥៣នាក់ ជូនសាលាបឋមសិក្សាខ្ចិះ ស្ថិតនៅភូមិខ្ចិះ ឃុំលុងឃុង ស្រុកបរកែវ ខេត្តរតនគីរី ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ:**

| | | |
|---|---|---|
| ១-លោក | ស៊ឹម វាចា | សប្បុរសជននៃអង្គការ អផ្ទហ្វាន់ |
| ២-លោក | ញាន សូរិយា . | សប្បុរសជននៃអង្គការ អផ្ទហ្វាន់ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ:**

| | | |
|---|---|---|
| -លោក | ស៊ឹម សូជា | សប្បុរសជននៃអង្គការ អផ្ទហ្វាន់ |

មាត្រា២._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តរតនគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៦៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជននិងអង្គការ ដែលបានផ្តល់ថវិកា តាមរយៈអង្គការ JHP ក្នុងការជួយសាងសង់អគារសិក្សាមួយចំនួន នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម ៖

១-លោក IWAKI SADAO បានផ្តល់ថវិកាចំនួន ៦២.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សាចំនួន០១ខ្នង មាន០៦បន្ទប់ និងបង្គន់អនាម័យ០១ខ្នង មាន០២បន្ទប់ ជូនដល់អនុវិទ្យាល័យផ្តុកដង្កោ ឃុំផ្ទះរុង។

២-សមាគម GIBRAL TAR SEIMEI GAKKOU KENSETSU YUSHI NO KAI បានផ្តល់ថវិកាចំនួន ៣១.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ ជូនដល់សាលាបឋមសិក្សាព្រែក០១ ស្ថិតក្នុងភូមិព្រែក ០១ ឃុំសំរោង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៦៨ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០៧ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក SAMUKAWA RYOSAKU ដែលបានផ្តល់ថវិកាចំនួន៥២.០០០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ជូនដល់សាលាបឋមសិក្សាស្រយ៉ូវជើង ស្ថិតនៅក្នុងភូមិស្រយ៉ូវជើង សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក Steven Fairelough ប្រធានអង្គការ Hands 4 Humanity ដែលបានផ្តល់ថវិកា ចំនួន៦៣.៥៦៩ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៣បន្ទប់ ព្រមទាំងបំពាក់សម្ភារៈបរិក្ខារគ្រប់គ្រាន់ បណ្ណាល័យ ០១បន្ទប់ ទីលានបាល់ទាត់ និងអណ្តូងទឹក០១ ជូនដល់សាលាបឋមសិក្សានាមរូប ស្ថិតនៅក្នុងឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៧០ .អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក ROBERT HARDING ប្រធាន Christian World Adoption ដែលបានផ្តល់ថវិកាសរុបចំនួន ២២.៥00 ដុល្លារអាមេរិក ក្នុងការជួយបង្កើតគម្រោង Day Care ជួយថែទាំនិងផ្តល់អាហារដល់កុមារ អាយុចាប់ពី ៣ ដល់ ៥ ឆ្នាំ ចំនួន២០៥នាក់ រស់នៅតាមព្រំដែន កម្ពុជា-ថៃ ដើម្បីអោយកុមារទាំងអស់នោះ មានឱកាសបានចូលរៀន នៅសាលាមត្តេយ្យសិក្សា ទំនប់ក៥ ស្ថិតនៅសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៧៦ . អនក្រ - បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកាសរុប ចំនួន ៥០.០០០ ដុល្លារអាមេរិក តាមរយៈអង្គការ អផ្ទហ្វាន់ ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ បង្គន់អនាម័យ ០២បន្ទប់ និងអណ្តូងទឹក០១ ព្រមទាំងផ្តល់សម្ភារៈសិក្សាមួយចំនួន និងសំលៀកបំពាក់ សម្រាប់សិស្សានុសិស្ស ចំនួន១៣៥នាក់ នៅសាលាបឋមសិក្សាខ្ចិះ ស្ថិតនៅភូមិខ្ចិះ ឃុំលុងឃុង ស្រុកបរកែវ ខេត្តរតនគីរី ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-HENDRY FAMILY | សប្បុរសជននៅប្រទេសអូស្ត្រាលី |
| ២-លោក STEVE ARGENT | សប្បុរសជននៅប្រទេសអូស្ត្រាលី |

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តរតនគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧២ .អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក KOKY SALY សប្បុរសជននៅប្រទេសអូស្ត្រាលី ដែលបានផ្តល់ថវិកាចំនួន ៣០.០០០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ និងធ្វើខ្លោងទ្វារ០១ ជូនដល់សាលាបឋមសិក្សាពពក ស្ថិតនៅឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០១០-១៩៤ ប្រ.ក

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមការអនុម័តរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១០
- បានឃើញសំណូមពរការងារចាំបាច់របស់ធនាគារជាតិនៃកម្ពុជា ។

## ស ម្រេ ច

**ប្រការ មួយ.-**

ប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ លេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ត្រូវបានកែសម្រួលដូចតទៅ ៖

**ប្រការ ៣.- ថ្មី**

ធនាគារជាតិនៃកម្ពុជា មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

១- អគ្គលេខាធិការដ្ឋាន គ្រប់គ្រងផ្ទាល់នូវ ៖

- ខុទ្ទកាល័យ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានគណនេយ្យ
- នាយកដ្ឋានគ្រប់គ្រងសាខា
- មណ្ឌលសិក្សាបច្ចេកទេសធនាគារ
- សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និង
- នាយកដ្ឋានព័ត៌មានវិទ្យា (IT) ។

២- អគ្គនាយកដ្ឋានបច្ចេកទេស គ្រប់គ្រងផ្ទាល់នូវ ៖
- នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានស្ថិតិ
- នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង
- នាយកដ្ឋានប្រតិបត្តិការ ។

៣- អគ្គនាយកដ្ឋានត្រួតពិនិត្យ គ្រប់គ្រងផ្ទាល់នូវ ៖
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានអាជ្ញាប័ណ្ណ
- នាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង និង
- នាយកដ្ឋានត្រួតពិនិត្យលើឯកសារ ។

៤- អគ្គាធិការដ្ឋាន គ្រប់គ្រងផ្ទាល់នូវ ៖
- នាយកដ្ឋានអធិការកិច្ច និង
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

៥- អគ្គបេឡា គ្រប់គ្រងផ្ទាល់នូវ ៖
- នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា និង
- នាយកដ្ឋានរោងពុម្ព ។

**ប្រការ ៤.~ ថ្មី**

អគ្គលេខាធិការដ្ឋាន ជាសេនាធិការផ្ទាល់របស់ថ្នាក់ដឹកនាំ ដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ច ដែលកំណត់ឲ្យខ្លួន សម្រាប់ការងារដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលជាទូទៅ រួមមានដូចជា :

- ទំនាក់ទំនងរដ្ឋបាលប្រចាំថ្ងៃ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិគ្រប់ប្រភេទ គម្រោងសាងសង់ ជួសជុល កែលម្អ គម្រោងចំណាយថវិកា ចំណូលនិងចំណាយហិរញ្ញកិច្ច ប័ណ្ណសារដ្ឋាន អាហារដ្ឋាន គិលានដ្ឋាន សន្តិសុខ សណ្តាប់ធ្នាប់ វិន័យការងារ និងការងារសង្គមកិច្ចផ្សេងទៀត ។

- គ្រប់គ្រងក្របខ័ណ្ឌនិងបៀវត្សមន្ត្រី-បុគ្គលិក វិនិយោគបេឡាសោធននិវត្តន៍ ក្នុងផលប្រយោជន៍សមូហភាព និងបណ្តុះបណ្តាលធនធានមនុស្ស ។ល។
- គ្រប់គ្រងទ្រព្យសម្បត្តិ និងប្រតិបត្តិការគ្រប់ប្រភេទតាមរយៈគណនេយ្យ
- សម្របសម្រួលនិងសហការដោះស្រាយនិងបំភ្លឺការងារនីតិកម្ម គតិយុត្តនិងវិវាទដែលពាក់ព័ន្ធដល់ធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធធនាគារ និង
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់ធនាគារជាតិនៃកម្ពុជា ។

អគ្គលេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយឬច្រើនរូបជួយធ្វើការតាមការចាំបាច់ ។ អគ្គលេខាធិការដ្ឋានមាននាយកដ្ឋានចំណុះចំនួន៥ មណ្ឌលសិក្សាបច្ចេកទេសធនាគារ និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តនីមួយៗ ដែលដឹកនាំដោយប្រធានឬនាយកមួយរូបអមដោយអនុប្រធានឬនាយករងមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៥.~ ថ្មី**

ខុទ្ទកាល័យ ជាសេនាធិការថ្នាក់ដឹកនាំ មានមុខងារ-ភារកិច្ច :

- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ និងសម្ភារៈរបស់ធនាគារជាតិនៃកម្ពុជា (រាប់បញ្ចូលទាំងសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្ត)
- ចរាចរលិខិតស្នាម ឯកសាររដ្ឋបាល ក្នុងបណ្តាញធនាគារជាតិនៃកម្ពុជា និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ជាមួយគ្រប់នាយកដ្ឋានជំនាញ និងគ្រប់គ្រងចំណូល- ចំណាយហិរញ្ញកិច្ចផ្ទៃក្នុង ធនាគារជាតិនៃកម្ពុជាទាំងមូល
- ធានាការអនុវត្តបទបញ្ជាផ្ទៃក្នុង រក្សារបៀបរៀបរយ សន្តិសុខ សុវត្ថិភាព និងវិន័យការងារ និង
- បំពេញភារកិច្ចតាមការប្រគល់ជូនរបស់ទេសាភិបាល ។

**ប្រការ ១២.~ ថ្មី**

អគ្គនាយកដ្ឋានបច្ចេកទេស ជាសេនាធិការជំនាញរបស់ថ្នាក់ដឹកនាំ ដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ច ដែលកំណត់ឲ្យខ្លួន សម្រាប់វិស័យសកម្មភាពដែលទាក់ទងនឹងអាជីវកម្មស្នូលនៃស្ថាប័ន រួមមានដូចជា :

- សិក្សា លើកគម្រោង និងធានាការអនុវត្តនយោបាយរូបិយវត្ថុ (រូបិយវត្ថុឥណទាន អត្រាប្តូរប្រាក់ និងអត្រាការប្រាក់) ដែលបានដាក់ចេញ
- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រក្រតី ដើម្បីរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាល និង/ឬដើម្បីផ្សព្វផ្សាយតាមគ្រាកំណត់ និង
- ប្រមូលផ្តុំទិន្នន័យស្ថិតិពីស្ថាប័ន-អង្គភាពដែលពាក់ព័ន្ធ ដើម្បីបម្រើឲ្យការសិក្សាវិភាគសេដ្ឋកិច្ចនិងដំឡើងតារាងជញ្ជីងទូទាត់ប្រចាំគ្រាកំណត់ ។

អគ្គនាយកដ្ឋានបច្ចេកទេស ត្រូវដឹកនាំដោយអគ្គនាយកបច្ចេកទេសមួយរូប អមដោយអគ្គនាយករងបច្ចេកទេសមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។ អគ្គនាយកដ្ឋានបច្ចេកទេសមាននាយកដ្ឋានចំនួន៤ នៅក្រោមចំណុះ ហើយនាយកដ្ឋាននីមួយៗដឹកនាំ ដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ១៣.~ ថ្មី**

អគ្គនាយកដ្ឋានត្រួតពិនិត្យ ជាសេនាធិការជំនាញរបស់ថ្នាក់ដឹកនាំ ដោយបំពេញភារកិច្ចតាមដែនសមត្ថកិច្ចដែលកំណត់ឲ្យខ្លួន សម្រាប់ប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រួមមានដូចជា :

- គ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានស្ទង់ការគណនី និងគ្រឹះស្ថានជម្រះបញ្ជីជាដើម
- រៀបចំផែនការ និងត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយប្រយោលទៅលើរបាយការណ៍ដែលទទួលបានប្រចាំគ្រា និងការត្រួតពិនិត្យដល់ទីកន្លែង
- ចូលរួមតាក់តែងសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិផ្សេងៗ និងចេញគំរូរបាយការណ៍ស្តង់ដារនានាដែលពាក់ព័ន្ធដល់ការគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុនស្ទង់ការគណនីឯករាជ្យ គ្រឹះស្ថានជម្រះបញ្ជី ក្រុមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានធនាគារដែលមានហានិភ័យជាប្រព័ន្ធ និងតាមដានការអនុវត្តត្រឹមត្រូវតាមលិខិតបទដ្ឋានទាំងនេះ
- ពិនិត្យសំណុំបែបបទនៃការស្នើសុំអាជ្ញាប័ណ្ណតាមភាពត្រឹមត្រូវនៃក្របខ័ណ្ឌច្បាប់ ដើម្បីលើកសំណើសុំចេញអាជ្ញាប័ណ្ណ ឬ ព្យួរ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានទាំងនោះក្នុងករណីល្មើសនឹងបទបញ្ញាជាធរមាន
- ដាក់ទណ្ឌកម្មខាងវិន័យចំពោះគ្រឹះស្ថានចំណុះច្បាប់ ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមិនអនុវត្តតាមច្បាប់និងបទបញ្ញា
- ចាត់នីតិវិធីតុលាការ បើសិនជាមានការរំលោភច្បាប់ដែលធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ
- សិក្សាស្រាវជ្រាវបញ្ហាប្រឈមនិងវាយតម្លៃហានិភ័យនៅក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ
- ជំរុញការអនុវត្តតាមបទដ្ឋានអន្តរជាតិ ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- រៀបចំយុទ្ធសាស្ត្រនិងគោលនយោបាយដើម្បីត្រៀមទប់ទល់វិបត្តិដែលអាចកើតមាន និង
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ទេសាភិបាល ។

អគ្គនាយកដ្ឋានត្រួតពិនិត្យត្រូវដឹកនាំដោយអគ្គនាយកត្រួតពិនិត្យមួយរូប និងអមដោយអគ្គនាយករងត្រួតពិនិត្យមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។ រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យនិងមុខងារ-ភារកិច្ចរបស់នាយកដ្ឋានជំនាញនីមួយៗ ត្រូវកំណត់ដោយប្រកាសដោយឡែក ។

**ប្រការ ពីរ.~**

ប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ លេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ បី.~**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងនាយកដ្ឋានសាមី ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ បួន.~**

ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ២០១០

**អគ្គទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ បី
" ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីជូនជ្រាបជាព័ត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី ✓
" ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

# អង្គភាពលេខធនាគារជាតិនៃកម្ពុជា

( ឧបសម្ព័ន្ធនៃប្រកាសលេខ :              ប្រ.ក ចុះថ្ងៃទី        ខែ វិច្ឆិកា ឆ្នាំ២០១០ )



ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៩៣៤ ឧ.រ.ថ.ភ.ឧ/២១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

